

# រឿងនិទានរបស់ព្រះចន្ទក្រហម

Asmaa Emara

Maia Aboud

Let's Read

The Asia Foundation



យប់នេះ ជីមមីរំភើបជាខ្លាំង ដោយសារបានមកលេងភូមិរបស់ជីតាខ្លួន។ អ្វីៗគ្រប់យ៉ាងនៅទីនេះគឺស្រស់ស្អាតណាស់ ហើយយប់នេះមានចន្ទគ្រាសទៀតផង។ ជីមមី ចូលចិត្តមើលព្រះចន្ទពណ៌ក្រហមដ៏ចម្លែកនេះ។



ជីមមី សម្រេចចិត្តគូររូបព្រះចន្ទដែលរះលើភូមិនេះ។ ប៉ុន្តែ រំពេចនោះ គេក៏ត្រូវបានរំខាន ដោយសំឡេងស្រែកខ្លាំងៗរបស់ អ្នកភូមិមួយក្រុម ដែលប្រមូលផ្តុំគ្នានៅខាងក្រៅ។



ជីមមីបានរត់ទៅសួរជីតារបស់គេ ៖ «តើមានរឿងអ្វីកើតឡើងហ្នឹងលោកតា?»
ជីតាបានប្រាប់ទៅជីមមីថា ៖ «អ្នកភូមិទាំងអស់មានការព្រួយបារម្ភអំពីព្រះចន្ទ។ នៅពេលដែលព្រះចន្ទផ្លាស់ប្តូរដូចនេះពួកគេមានជំនឿថានឹងមានបិសាចចចកចូលមក។ ដូចនេះមានតែការស្រែកនេះទេដែលអាចដេញបិសាចចចកនោះ ឲ្យចេញទៅឆ្ងាយបាន។
ដោយសារតាជាមេភូមិ ដូចនេះតាត្រូវប្រាប់ពួកគេអំពីពេលវេលាដែលត្រូវចាប់ផ្តើម ។»
ជីមមីមានការភ្ញាក់ផ្អើលជាខ្លាំង ហើយគេបានសួរទៅជីតាគេថា ៖ «តើលោកតាពិតជាជឿលើជំនឿនេះមែនទេ ?»



ជីតាក៏បានឆ្លើយទៅវិញថា៖ «នេះគឺជាទំនៀមទំលាប់របស់ពួកយើងតាំងពីយូរលង់ណាស់មកហើយ។ ចៅនៅក្មេងណាស់ ចៅមិនយល់នោះទេ។»

ប៉ុន្តែជីមមីនៅតែនិយាយតវ៉ាទៀតថា៖ «នេះគ្រាន់តែជារឿងព្រេងទេលោកតា ព្រះចន្ទនឹងគង់តែត្រលប់ទៅសភាពដើមវិញនោះទេ។»

លោកតានៅតែមិនជឿ ហើយបានតបទៅវិញថា៖ «មិនមែនទេជីមមី មានតែពិធីរបស់ពួកយើងទេ ដែរអាចជួយព្រចន្ទបាន។»



ជីមមីក៏ស្រែកឡើង៖ «ពិតជាមិនគួរឱ្យជឿទេ!..»



«តើលោកតាជឿខ្ញុំទេ បើសិនជាខ្ញុំអាចរកភស្តុតាងមកបញ្ជាក់ថា ការគោះឆ្នាំងនិងខ្ទះនេះ មិនអាចជួយអ្វីដល់ព្រះចន្ទបាន?» លោកតាឆ្លើយតបថា៖ «តាអាចចាំមើលបាន ប៉ុន្តែអ្នកភូមិប្រហែលមិនអាចចាំបានទេ។»



ជីមមីបន្ត៖ «លោកតា ចាំមួយភ្លែត។ ខ្ញុំគិតថា ខ្ញុំដូចជា
បានឃើញសៀវភៅ វិទ្យាសាស្ត្រមួយក្បាលនៅជាន់ខាងលើ!..»



ជីមមីបានព្យាយាមរកសៀវភៅវិទ្យាសាស្ត្រ ដែលពន្យល់ពី
បាតុភូតចន្ទគ្រាស ប៉ុន្តែគេរកមិនឃើញនោះទេ។



ជីមមីបានដើរចុះកាំជណ្ដើរមួយៗ។ ឃើញដូច្នេះ លោកតាក៏បាននិយាយថា៖ «មើលទៅចៅ ដូចជាមិនបានរកឃើញសៀវភៅនោះទេ។ តានឹងទៅឲ្យសញ្ញាដល់អ្នកភូមិហើយ។»



ពេលដែលពួកគេសម្លឹងមើលទៅក្រៅបង្អួច ជីមមីបាននឹកឃើញ ដល់ការសង្កេតវិទ្យាសាស្ត្រនៅលើភ្នំ។
ជីមមីក៏និយាយថា៖ « ខ្ញុំនឹងបង្ហាញលោកតា។ លោកតាទៅ កន្លែងសង្កេតជាមួយចៅមក!.. តោះ!.. យើងទៅ!..»



នៅតាមផ្លូវទៅកន្លែងសង្កេតនោះ អ្នកភូមិបានមករារាំងពួកគេ។ អ្នកភូមិបានចោទសួរថា៖ «តើអ្នកទាំងពីរកំពុងទៅណា? ពួកយើងកំពុងរង់ចាំសញ្ញាគោះចានឆ្នាំងដើម្បីជួយសង្គ្រោះព្រះចន្ទ!..»
ជីមមីបានឆ្លើយតបថា៖ «សូមអ្នកទាំងអស់គ្នារង់ចាំពួកយើង។ ពួកយើងនឹងត្រឡប់មកវិញឆាប់ៗនេះ!»



នៅមន្ទីរអង្កេត ជីមមីនិងជីតារបស់គេ ជួបនឹងអ្នកវិទ្យាសាស្រ្ត ម្នាក់។

ជីមមីសួរ៖ «តើអ្នកអាចជួយពន្យល់ជីតារបស់ខ្ញុំ ពីអ្វីដែល កើតឡើងនៅក្នុងពេលចន្ទគ្រាសបានដែរឬទេ?»

អ្នកវិទ្យាសាស្រ្តឆ្លើយតប ៖ «ប្រាកដជាបាន!.. ពេលនេះ ផែនដី កំពុងតែស្ថិតនៅចន្លោះព្រះអាទិត្យនិងព្រះចន្ទ។ ដូច្នេះហើយ ស្រមោលរបស់ផែនដីក៏បានធ្វើឲ្យព្រះចន្ទងងឹត។»

ជីតានិយាយ៖ «គួរឱ្យចាប់អារម្មណ៍ណាស់តើ!..»

អ្នកវិទ្យាសាស្រ្តរូបនេះបន្តថា៖ «ពន្លឺតូចៗមួយចំនួនដែល ជះពីព្រះអាទិត្យ ឆ្លងកាត់បរិយាកាសផែនដី វាធ្វើឲ្យព្រះចន្ទ ប្រែជាពណ៌ក្រហម។ សាកមើលតាមរយៈកែវយឺតនេះមើល!.. ប្រសិនបើអ្នកមើលមួយភ្លែត អ្នកនឹងឃើញស្រមោលឆ្លងកាត់

លើព្រះចន្ទ។»



លោកតានិយាយថា ៖ «អូ ខ្ញុំឃើញហើយ!.. វាគ្មានបិសាចចចក
អីនោះទេ។ វាគ្រាន់តែជាបាតុភូតធម្មជាតិតែប៉ុណ្ណោះ។»
ជីមមីបានស្រែកឡើងថា ៖ «ទីបំផុតលោកតាព្រមជឿខ្ញុំហើយ
មែនទេ?»



ជីមមី និងជីតារបស់គេ វិលត្រឡប់មកភូមិវិញ ហើយបានឃើញ គ្រប់គ្នា កំពុងរង់ចាំពួកគេយ៉ាងអន្ទះសា។



ស្ត្រីចំណាស់ម្នាក់ក៏បាននិយាយបន្ថែមថា៖ «យើងដឹងហើយ ថាស្ដេចចចកកំពុងតែសម្លាប់ព្រះចន្ទ ហើយវានឹងមិនចាកចេញនោះទេ លុះណាតែយើងបន្លាចវា។ នេះជាវិធីដ៏ជោគជ័យតាំងពីយូរយារណាស់មកហើយ»

ក្មេងម្នាក់ក៏បានស្រែកថា៖ «ខ្ញុំក៏ចង់គោះឆ្នាំងរបស់ខ្ញុំដែរ!..»



លោកតាមានការខកចិត្តជាខ្លាំងចំពោះអ្នកភូមិ ដែលមិនព្រម
ទទួលស្គាល់ការពិតដែលគាត់បានប្រាប់។ ជីមមីក៏នឹកឃើញ
គំនិតល្អមួយ គេក៏ខ្សឹបតិចៗទៅលោកតា។



បន្ទាប់មកជីមមី ក៏ងាកទៅរកអ្នកភូមិ រួចនិយាយ៖ «សូមអ្នកទាំងអស់គ្នាស្តាប់ខ្ញុំ!.. នៅតាមផ្លូវចុះពីភ្នំ ពួកយើងបានជួបបុរសម្នាក់ ដែលឮសំឡេងចចក ដែលនៅមិនឆ្ងាយប៉ុន្មានពីទីនេះនោះទេ ហើយបើយើងគោះឆ្នាំង ចានរបស់យើងពេលនេះ ចចកនឹងដឹងថាពួកយើងនៅទីនេះ ហើយវានឹងមកវាយប្រហារយើងជំនួសព្រះចន្ទមិនខាន!..»



គ្រប់គ្នាមានអារម្មណ៍ព្រឺព្រួចហើយខ្លាចសត្វចចកជាខ្លាំង។



ពួកគេចាប់ផ្តើមទម្លាក់ឆ្នាំងចានចោល បន្ទាប់មករត់ទៅផ្ទះរៀងៗខ្លួនយ៉ាងលឿនជាទីបំផុត។



មិនយូរប៉ុន្មាន អ្នកភូមិក៏បានកត់សំគាល់ដូចៗគ្នា។ ពួកគេមានការភ្ញាក់ផ្អើល ប៉ុន្តែសប្បាយរីករាយដែលបានដឹងថាមេភូមិ និងចៅប្រុសរបស់គាត់និយាយត្រូវ។ នៅពេលមានចន្ទគ្រាសលើកក្រោយ ពួកគេនឹងប្រារព្ធពិធីអបអរព្រះចន្ទ និងបាតុភូតធម្មជាតិដ៏អស្ចារ្យនេះ!..



ចប់

## Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*Legend of the Red Moon*, Author: Asmaa Emara. Illustrator: Maia Aboud. Published by Asafeer, © Asafeer. Released under CC BY-NC-SA 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC-SA 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc-sa/4.0/
Contributing translators: Somey Chheang and Kem Lyheang